**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃ កងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះ ហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២
ព្រះហស្ថលេខា និង ត្រា ហត្ថលេខា និង ត្រា
**នរោត្តម រណឬទ្ធិ** **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៤៥ អនក្រ.បក**

**ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋានអធិការកិច្ច**

**របស់រាជរដ្ឋាភិបាល**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការកំណត់ភារកិច្ច និង សមត្ថកិច្ចរបស់ទេសរដ្ឋមន្ត្រី ទទួលបន្ទុក អធិការកិច្ច
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែល រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តកាលពីថ្ងៃទី ១៩ ខែកក្កដា

ឆ្នាំ ១៩៩៤ និងប្រកាសឱ្យប្រើតាមព្រះរាជក្រមរបស់ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច .

## សម្រេច

**មាត្រា ១ :** ត្រូវបានបង្កើត អគ្គលេខាធិការដ្ឋានអធិការកិច្ចរបស់រាជរដ្ឋាភិបាលមួយមានទីតាំងស្ថិតនៅ ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីធ្វើជាសេនាធិការឱ្យទេសរដ្ឋមន្ត្រីទទួល បន្ទុកអធិការកិច្ច ។

**មាត្រា ២ :** អគ្គលេខាធិការដ្ឋានអធិការកិច្ច មានភារកិច្ច ÷

- គ្រប់គ្រងកិច្ចការរដ្ឋបាលដោយឡែក ក្នុងក្របខ័ណ្ឌការងារអធិការកិច្ចរាជរដ្ឋាភិបាល ដែលទទួលខុសត្រូវដោយទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច ។
- ក្តាប់សភាពការណ៍ សិក្សាស្រាវជ្រាវបញ្ហាគន្លឹះនានារបស់រាជរដ្ឋាភិបាល លើគ្រប់វិស័យ ដើម្បីជួយទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច កសាងផែនការកម្មវិធីការងារ និង ចាត់តាំងអនុវត្តរាល់ផែនការ និងកម្មវិធីទាំងនោះតាមនីតិវិធីអធិការកិច្ចសមស្របតាមកាលៈទេសៈជាក់ស្តែង ។
- ជំនួយការផ្ទាល់ជូនទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច ក្នុងការតាមដានត្រួតពិនិត្យអំពីការប្រព្រឹត្តិទៅ និងការធ្វើសកម្មភាពរបស់គ្រប់ក្រសួង ស្ថាប័នខេត្ត-ក្រុង នូវរាល់ការអនុវត្តន៍គោលការណ៍ គោលនយោបាយ អនុក្រឹត្យ សេចក្តីសំរេច សារាចរ សារាចរណែនាំ និងលិខិតបទដ្ឋាននានារបស់រាជរដ្ឋាភិបាល ។
- ទទួលពិនិត្យរឿងវិវាទរដ្ឋបាល ស្ថិតក្នុងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ដាក់ជូនទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ចពិនិត្យសំរេច ដើម្បីចាត់ចែងអោយមាន ការដោះស្រាយត្រឹមត្រូវតាមនិតិវិធី និង ច្បាប់របស់រដ្ឋ ។
- បង្កលក្ខណៈងាយស្រួលដល់បេសកជន ឬប្រតិភូ ដែលចុះធ្វើអធិការកិច្ចតាំងពីពេលចាប់ផ្តើមរហូតដល់ពេលបញ្ចប់បេសកកម្ម ។

- ជួយទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច ដើម្បីធ្វើរបាយការណ៍សរុប អំពីសកម្មភាព និង លទ្ធផលការងារអធិការកិច្ចប្រចាំខែ ត្រីមាស ឆមាស ប្រចាំឆ្នាំ ជូនរាជរដ្ឋាភិបាល ។
- ទទួលភារកិច្ចផ្សេង ។ ទៀត ដែលទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ចប្រគល់អោយ ។

**មាត្រា ៣ :** អគ្គលេខាធិការដ្ឋានអធិការកិច្ច មានសិទ្ធិ ÷

- កោះអញ្ជើញមន្ត្រី បុគ្គលិករាជការ ឬ ជនដែលពាក់ព័ន្ធ ដើម្បីសាកសួរពត៌មាន ផ្លាស់ប្តូរយោបល់ ផ្តល់ឯកសារ ឬចូលរួមសហការក្នុងសកម្មភាពធ្វើអធិការកិច្ច ។
- ក្រោយពេលធ្វើអធិការកិច្ចមួយលើ ៗ មានសិទ្ធិធ្វើរបាយការណ៍តាមការធ្វើអធិការកិច្ចជាក់ស្តែង ដោយបញ្ជាក់អំពីការធ្វើត្រូវ ធ្វើខុស រួចសន្និដ្ឋាន និងលើកសំណូមពរជូនទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ចពិនិត្យ ដើម្បីឯកភាពធ្វើជូនរាជរដ្ឋាភិបាលសំរេច ។
- ចាត់ឱ្យចុះផ្សាយជាសាធារណៈនូវលទ្ធផល នៃ ការងារអធិការកិច្ច ដែលរាជរដ្ឋាភិបាលបានសំរេចហើយ ។

**មាត្រា ៤ :** អគ្គលេខាធិការដ្ឋានអធិការកិច្ច ដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ និងមាននាយអធិការមួយចំនួនទៀតថ្នាក់ស្មើប្រធាននាយកដ្ឋានស្ថិតក្រោមឱវាទ ជួយធ្វើការងារជំនាញអធិការកិច្ច ។

**មាត្រា ៥ :** ក្របខ័ណ្ឌមន្ត្រីរាជការនៅអគ្គលេខាធិការដ្ឋានអធិការកិច្ច អាស្រ័យដោយទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ចកំណត់ ដើម្បីលើកសំណើជូនរាជរដ្ឋាភិបាលពិនិត្យសំរេច ។

**មាត្រា ៦ :** ការចំណាយទាំងអស់សំរាប់សកម្មភាពរបស់អគ្គលេខាធិការដ្ឋានអធិការកិច្ចស្ថិតក្នុងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៧ :** ការរៀបចំ និង ការប្រព្រឹត្តិទៅ នៃអគ្គលេខាធិការដ្ឋានអធិការកិច្ច ត្រូវកំណត់ដោយប្រកាសរបស់ទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច ។

**មាត្រា ៨** : ទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និងអភិបាលខេត្ត - ក្រុង ត្រូវទទួល អនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង ៗ ខ្លួន ។

**មាត្រា ៩** : អនុក្រឹត្យនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៦៣ អនក្រ.តត**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ .
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ .